## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

# សារលិខិតអបអរសាទរ

## សូមគោរពជូន

## សម្តេច ឥស្សរទិទេសបញ្ញា ហោ ណាំហុង

## ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

សម្តេច ឥស្សរវិទេសបញ្ញា ជាទីគោរព !

នៅក្នុងឱកាសដ៏មហាឧត្តុង្គឧត្តមប្រសើរថ្លៃថ្លា ប្រកបដោយក្តីសោមនស្សរីករាយ មានអត្ថន័យដ៏ជ្រាលជ្រៅនេះ ខ្ញុំបាទនិងភរិយាសូមចូលរួមអបអរសាទរយ៉ាងក្លៀវក្លាចំពោះ **ឯកឧត្តមកិត្តិបរិក្សបណ្ឌិត** ដែលត្រូវបាន**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត** ប្រោសព្រះរាជទានគោរមងារ ជា "**សម្តេច ឥស្សរវិទេសបញ្ញា**"។

នៅក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមសម្តែងការកោតសរសើរដោយស្មោះចំពោះស្នាដៃដ៏ធំធេង និងកិច្ចខិតខំប្រឹងប្រែងរបស់**សម្តេច ឥស្សរវិទេសបញ្ញា** ក្នុងបុព្វហេតុចូលរួមកសាងប្រទេសជាតិពីបាតដៃទទេ រហូតទទួលបានសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។ **សម្តេច ឥស្សរវិទេសបញ្ញា** បានបំពេញបេសកកម្មជាប្រវត្តិ-សាស្ត្រ បម្រើជាតិ និងប្រជាជន តាមរយៈការដឹកនាំដ៏ប៉ិនប្រសប់ក្នុងវិស័យការទូត និងសហប្រតិបត្តិការអន្តរជាតិ ធ្វើឱ្យកិត្តិនាមរបស់ប្រទេសកម្ពុជា ត្រូវបានលើកតម្កើងលើឆាកតំបន់ និងអន្តរជាតិជាបន្តបន្ទាប់។

ជាថ្មីម្តងទៀត ខ្ញុំបាទនិងភរិយាសូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ វត្ថុស័ក្តិសិទ្ធិក្នុងលោក និងទេវតាតាមជួយបីបាច់ថែរក្សាប្រទានពរជ័យ សិរីសួស្តី ជ័យមង្គល វិបុលសុខ បវរមហាប្រសើរគ្រប់ប្រការជូនចំពោះ**សម្តេច ឥស្សរវិទេសបញ្ញា និងលោកជំទាវ** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រីទាំងអស់ សូមបានប្រកប ដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេច ឥស្សរវិទេសបញ្ញា ហោ ណាំហុង ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទនិងភរិយា។

ថ្ងៃចន្ទ ១៥រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**